00485556

D97/15/8

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ ៣៨)

ភាគីដាក់ឯកសារ: សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១០

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 15 / 03 / 2010
ម៉ោង (Time/Heure): 11:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ~~កម្មាធិការ~~ អបជ: សាធារណៈ / Public CR

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់មេធាវីការពារក្តីចំពោះសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញានៅ**
**នឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងការអនុវត្តសហឧក្រិដ្ឋកម្មរួម**

---

**ដាក់ដោយ៖**

**សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ**

លោក ផាត់ ពៅសៀង

កញ្ញា Diana ELLIS QC

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 15 / 03 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង

ដើមបណ្តឹងរដ្ឋប្បវេណីគ្មានតំណាងទាំងអស់

**ផ្ញើជូន៖**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ហួត វុទ្ធី

ចៅក្រម Rowan DOWNING

ចៅក្រម ន៉ី ធុល

ចៅក្រម Katinka LAHUIS

**ចៅក្រម ប៉ែន ពេជ្រសាលី**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

# I សេចក្តីផ្តើម

1. កាលពីថ្ងៃទី ៨ ខែធ្នូ ឆ្នាំ២០០៩ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានចេញ "ដីកាសម្រេចស្តីពីការអនុវត្តនៅ អវតក នៃទម្រង់នៃការទទួលខុសត្រូវដែលស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម"(**ដីកា**)[1] ។ មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ (**ជនត្រូវចោទ**) កាលពីថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៩ បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះ (**បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ**)[2] ដែលបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធចោលដីកានេះ និងសម្រេចថា អវតក ពុំមានយុត្តាធិការលើសហឧក្រិដ្ឋកម្មរួម (JCE) ជាទម្រង់នៃការទទួលខុសត្រូវនៅក្នុងសំណុំរឿង ០០២ នោះទេ ។ ផ្ទុយពីការអះអាងរបស់មេធាវីការពារក្តី ប្រសិនបើអង្គបុរេជំនុំជម្រះយល់ឃើញថាមានយុត្តាធិការមែន នោះមេធាវីការពារក្តីស្នើសុំអង្គបុរេជំនុំជម្រះបង្គាប់ថា អវតក ពុំមានយុត្តាធិការដើម្បីអនុវត្ត JCE ទម្រង់ទី៣ លើករណីនេះទេ ។ម្យ៉ាងទៀត មេធាវីការពារក្តីយល់ឃើញថា សហព្រះរាជអាជ្ញាពុំបានផ្តល់មូលហេតុគ្រប់គ្រាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរចំពោះ JCEទម្រង់ទី១ និងទម្រង់៣ឡើយ។ ហេតុដូច្នេះ ទម្រង់នៃការទទួលខុសត្រូវដែលស្គាល់ថាជា សហកម្មឧក្រិដ្ឋកម្មរួម មិនអាចអនុវត្តចំពោះសំណុំរឿង០០២ នោះទេ ។ ជនត្រូវចោទពីរនាក់ផ្សេងទៀតក៏បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះដែរ (**បណ្តឹងឧទ្ធរណ៍របស់ អៀង សារី**[3] និង **បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន**[4]) បណ្តឹងទាំងពីរនេះហៅថា **បណ្តឹងឧទ្ធរណ៍**)។

2. នៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១០ ការិយាល័យសហព្រះរាជអាជ្ញា បានឆ្លើយតបចំពោះបណ្តឹងឧទ្ធរណ៍ទាំងនេះ (**ចម្លើយតបរបស់ កសព**)[5]។ នៅថ្ងៃទី៩ ខែមិនា ឆ្នាំ ២០១០ អង្គបុរេជំនុំជម្រះបានជូនដំណឹងដល់ភាគីទាំងអស់អំពីសេចក្តីសម្រេចរបស់ខ្លួនទៅលើបណ្តឹងឧទ្ធរណ៍ទាំងអស់ ដោយ

---

[1] កសចស "ដីកាសម្រេចលើការអនុវត្តនៅ អវតក នៃទម្រង់នៃការទទួលខុសត្រូវ ដែលស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៩, ឯកសារលេខ D97/13 ។

[2] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចស្តីពីការអនុវត្តនៅ អវតក នូវទម្រង់នៃការទទួលខុសត្រូវ ដែលស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៩, ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៩, ឯកសារលេខ D97/15/1។

[3] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាស្តីពីការអនុវត្តនៅ អវតក នូវទម្រង់នៃការទទួលខុសត្រូវដែលស្គាល់ថាជា សហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២២ ខែ មករា ឆ្នាំ២០១០, ឯកសារលេខ D97/14/5 ។

[4] បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាស្តីពីការអនុវត្តនៅ អវតក នូវទម្រង់នៃការទទួលខុសត្រូវដែលស្គាល់ថាជា សហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី១៨ ខែ មករា ឆ្នាំ២០១០, ឯកសារលេខ D97/16/1 ។

[5] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ២០១០ ចំពោះបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសហកម្មឧក្រិដ្ឋរួម, ឯកសារលេខ D97/15/6 ។

ផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរតែប៉ុណ្ណោះ និងបានបង្គាប់ឲ្យមេធាវីការពារក្តីដាក់ចម្លើយតប ស្របតាមមាត្រា ៨.៤ នៃសេចក្តីណែនាំស្តីពីការដាក់ឯកសារ[6]។

3. អំណះអំណាងភាគច្រើនក្នុងចម្លើយតប ត្រូវបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់របស់ អៀង ធីរិទ្ធ អៀង សារី និងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ។ ជាសេចក្តីយោង មេធាវីការពារក្តីសូមដាក់បញ្ចូលអំណះអំណាងដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ។

## II ការឆ្លើយតបចំពោះការជំទាស់បឋមរបស់ កសព

4. ទាញចេញពីដីកាសម្រេចនេះ កសព លើកឡើងនូវអំណះអំណាងចំនួនប្រាំក្នុងការជំទាស់សិទ្ធិរបស់ជនត្រូវចោទដើម្បីប្តឹងឧទ្ធរណ៍ ។ ខណៈដែលអំណះអំណាងជាច្រើនពាក់ព័ន្ធជាមួយតែបណ្តឹងឧទ្ធរណ៍របស់ អៀង សារី តែប៉ុណ្ណោះ ហេតុដូច្នេះ មេធាវីការពារក្តីនឹងលើកអំណះអំណាងនានាដែលពាក់ព័ន្ធជាមួយបណ្តឹងឧទ្ធរណ៍របស់ខ្លួនតែប៉ុណ្ណោះ ។

### ២.១ ដីកាសម្រេចនេះ គឺជា "ដីកា"មួយ ហើយមិនមែនជា "សេចក្តីប្រកាស" នោះទេ

5. កសព សំដៅទៅរកដីកានេះថាជា "សេចក្តីប្រកាស" ដែលផ្ទុយទៅនឹង "ដីកា"[7]។ ដូចដែលបង្ហាញតាមរយៈឈ្មោះរបស់ឯកសារស្រាប់ (ដីកាសម្រេចស្តីពីការអនុវត្តនៅ អវតក នូវទម្រង់នៃការទទួលខុសត្រូវដែលស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម) មេធាវីការពារក្តីយល់ឃើញថា វាជាដីកាសម្រេចមួយ ហើយមិនមែនជាប្រភេទផ្សេងទៀតរបស់ឯកសារច្បាប់នោះទេ។ ការអះអាងដោយ កសព ដែលថាដីកាសម្រេចរបស់ កសចស គឺជា "សេចក្តីប្រកាស" គឺជាការអះអាងគ្មានមូលដ្ឋានដែលបង្ហាញឲ្យឃើញថា ពុំមានប្រភេទនៃឯកសារដែលពិពណ៌នាថាជាសេចក្តីប្រកាស ដែលមិនអាចរកឃើញនៅក្នុងវិធាននៃផ្ទៃក្នុង នោះឡើយ។ បន្ថែមពីលើនេះ ការប្រៀបធៀបដែលធ្វើឡើងដោយ កសព រវាង "លិខិត" ជាច្រើនដែលបញ្ជូនមក កសចស និងដីកាសម្រេចរបស់ កសចស គឺមិនមានភស្តុតាងបញ្ជាក់នោះទេ។

---

[6] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីសហកម្មឧក្រិដ្ឋរួម ដោយផ្អែកលើសេចក្តីសន្និដ្ឋានលាយលក្ខអក្សរតែប៉ុណ្ណោះ និងសេចក្តីបង្គាប់ដាក់ចម្លើយតប ចុះថ្ងៃទី៩ ខែមិនា ឆ្នាំ ២០១០, ឯកសារលេខ D97/15/7 ។

[7] ចម្លើយតបរបស់ កសព, ខថាខណ្ឌទី៥ -៦ ។

6. មេធាវីការពារសូមស្នើបន្ថែមទៀតថា កសព ត្រូវតែបញ្ឈប់លើកឡើងនូវអំណះអំណាងបែបនេះ ។ នៅក្នុងសំណុំរឿង ០០១ (ករណី ឌុច) កសព បានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស លើបញ្ហានៃភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម[8]។ នៅក្នុងករណីនោះ សហព្រះរាជអាជ្ញាបានស្នើថា បញ្ហានៃភាពអនុវត្តបាននៃ JCE មិនគ្រាន់តែជាសេចក្ដីប្រកាសនោះទេ ប៉ុន្តែវាពាក់ព័ន្ធជាមួយបញ្ហាយុត្តាធិការដែលជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍ផងដែរ ។ ឥឡូវនេះ កសព បែរជាស្វែងរកការទាញអំណះអំណាផ្ទុយទៅវិញ ប៉ុន្តែ ខកខានមិនបានផ្ដល់មូលដ្ឋានណាមួយ ដែលករណីទាំងពីរអាចញែកឲ្យដាច់ពីគ្នាយ៉ាងត្រឹមត្រូវនោះទេ។ កសព បានទទួលស្គាល់នៅក្នុងករណីទាំងពីរនេះថា បញ្ហានេះអាចត្រូវបានពិនិត្យឡើងវិញនៅសវនាការ ។ តាមពិតនៅក្នុងករណីឌុច កសព បានលើកបញ្ហានេះម្ដងទៀតនៅសវនាការ ។

7. ជាផលវិបាក ដីកាសម្រេចរបស់ កសចស ត្រូវតែបានចាត់ទុកថាជា "ដីកា" មួយ ស្របតាមវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង ហើយអំណះអំណាងរបស់ កសព ត្រូវតែបដិសេធចោល ។

## ២.២ ដីកាសម្រេចទាក់ទងទៅនឹងការបញ្ជាក់ពីយុត្តាធិការ

8. នៅក្នុងកថាខណ្ឌទី៧-៩ នៃសេចក្ដីសន្និដ្ឋានតប សហព្រះរាជអាជ្ញាថ្លែងថា ដីកាសម្រេចនេះមិនបានបញ្ជាក់ពីយុត្តាធិការរបស់ អវតកទេ។ ផ្ទុយពីការអះអាងរបស់ កសព មេធាវីការពារក្ដីយល់ឃើញថាដីកាសម្រេចនេះបានបញ្ជាក់ពីយុត្តាធិការលើទម្រង់នៃការទទួលខុសត្រូវដែលស្គាល់ថាជា សហឧក្រិដ្ឋកម្មរួមសម្រាប់ជនត្រូវចោទ និងសហជនត្រូវចោទរបស់គាត់នៅក្នុងសំណុំរឿង ០០២ ។

9. ដូចដែលបានបញ្ជាក់អះអាងដោយ កសចស បញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងដីកាសម្រេចនេះមិនមែនជាសំណើសុំមានសេចក្ដីប្រកាសពីដំណោះស្រាយនោះទេ ដែលមិនត្រូវលើកឡើងដោយ កសចស នៅដំណាក់កាលនេះឡើយ ។ ទាក់ទងនឹងចំនុចនេះ កសចស បានយល់ឃើញយ៉ាងត្រឹមត្រូវថា:

> ហេតុដូច្នេះ បើទោះបីសហចៅក្រមស៊ើបអង្កេតមិនពិចារណាលើសំណើដែលស្នើសុំការសេចក្ដីប្រកាសពីដំណោះស្រាយក៏ដោយ ប៉ុន្តែនៅក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេតចាំបាច់ត្រូវតែឆ្លើយតបទៅនឹងសំណើនេះ ដើម្បីផ្ដល់ព័ត៌មានគ្រប់គ្រាន់ស្ដីពីទម្រង់នៃការទទួលខុសត្រូវ ដែលមិនត្រូវបានចែងយ៉ាងច្បាស់នៅច្បាប់ អវតក និង កិច្ចព្រមព្រៀង ។ នៅក្នុងករណីនេះ សហចៅក្រមអង្កេតយល់ឃើញថា សំណើមានលក្ខណៈច្បាស់លាស់ និងសមហេតុផល ។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតបដិសេធ

---

[8] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាដំណោះស្រាយបញ្ជូនជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច"ទៅជំនុំជម្រះ ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០០៨, ថ្ងៃទី៥ ខែ កញ្ញា ឆ្នាំ ២០០៨, សំណុំរឿងលេខ ០០១ ឯកសារ D99/3/3។ ចម្លើយតបទៅនឹងសេចក្ដីសន្និដ្ឋានតបរបស់ កសព ចំពោះបណ្ដឹងឧទ្ធរណ៍លើការអនុវត្តនូវទម្រង់ឧក្រិដ្ឋកម្មរួម

ចោលសំណើរបស់ កសព ដែលស្នើសុំឱ្យសម្រេចថា សំណើរបស់មេធាវីការពារក្ដី គឺជាសំណើដែលមិនអាចទទួលយកបានដោយសារតែ[9] ។

10. ហេតុដូច្នេះ ដីកាសម្រេចនេះលើកឡើងដោយផ្ទាល់ពីយុត្តាធិការរបស់ អវតក ដើម្បីចោទប្រកាន់ជនត្រូវចោទពីទម្រង់នៃការទទួលត្រូវ ដែលគេស្គាល់ថាជា JCE ។ ខណៈដែល កសចស ត្រូវ បានស្នើសុំឱ្យសម្រេចលើបញ្ហាថាតើ JCE អាចអនុវត្តបាន ឬមិនអាចអនុវត្តនៅពេលវេលាពាក់ព័ន្ធនៅកម្ពុជា នោះចម្លើយចំពោះសំនួរនេះ គឺសម្រេចពីយុត្តាធិការរបស់ អវតក ។

11. ម្យ៉ាងវិញទៀត ទាក់ទងនឹងយុត្តាធិការរបស់តុលាការនេះ ដើម្បីកាត់សេចក្ដីជនត្រូវចំពោះទម្រង់នៃការទទួលខុសត្រូវជាក់លាក់នេះ មេធាវីការពារក្ដីសូមលើកអំណះអំណាងថា ទម្រង់នៃការទទួលខុសត្រូវនេះមិនត្រូវបានពន្យល់ឱ្យបានត្រឹមត្រូវនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យទៅស៊ើបសួរទេ ។

12. ហេតុដូច្នេះ មេធាវីការពារក្ដីយល់ឃើញថា អំណះអំណាងដែលលើកឡើងដោយ កសព ត្រូវតែបដិសេធចោល ។

## ២.៣ ការយល់ខុសទាក់ទងនឹងការអនុវត្តវិធាន ២១

13. នៅក្នុងកថាខណ្ឌទី ១៤-១៧ នៃចម្លើយតបរបស់សហព្រះរាជអាជ្ញា បានសំដៅទៅលើវិធាន ២១ ដោយបានសង្កត់ធ្ងន់ពីសារៈសំខាន់ដែលថាដំណើរការនីតិវិធី គឺ "មានយុត្តិធម៌ និងមានល្បឿនលឿន"។ កសព សំអាងលើបទបញ្ញត្តិនេះ ដែលបង្កើតឡើងដើម្បីការពារសិទ្ធិរបស់ជនត្រូវចោទ ដើម្បីបដិសេធសិទ្ធិរបស់ជនត្រូវចោទដែលមានចែងយ៉ាងច្បាស់នៅក្នុងវិធានផ្ទៃក្នុង ដើម្បីជំទាស់ដីកាសម្រេចរបស់ កសចស ដ៏មានសារៈសំខាន់នេះ ។ កសព បានផ្ដល់មូលហេតុថា ការដែលមិនអនុញ្ញាតឱ្យប្ដឹងឧទ្ធរណ៍នេះ នឹងមិនរំលោភសិទ្ធិរបស់ជនត្រូវចោទ ក្រោមវិធាន ២១ ដែរ ។ ថាតើសិទ្ធិរបស់ជនត្រូវចោទត្រូវបានរំលោភ ឬមិនត្រូវបានរំលោភ គឺមិនពាក់ព័ន្ធនៅកិច្ចពិភាក្សានេះទេ ។ ពុំមានលក្ខខណ្ឌតម្រូវបែបនេះ បង្កប់នៅក្នុងបទបញ្ញត្តិទាក់ទងនឹងបណ្ដឹងឧទ្ធរណ៍នៃវិធានផ្ទៃក្នុងនោះដែរ ។ វិធានផ្ទៃក្នុងមិនបានចែងថា ដើម្បីប្ដឹងឧទ្ធរណ៍ ជនត្រូវចោទត្រូវតែបង្ហាញពីការរំលោភវិធាន ២១ ។

14. នៅចំពោះទាំងផ្នែកនេះ កសព បានចោទប្រកាន់ថា បញ្ហានេះ គឺគ្រាន់តែជាទ្រឹស្ដីប៉ុណ្ណោះ ដែលជាការចោទប្រកាន់មិនត្រឹមត្រូវនោះទេ។ តាមពិត ចម្លើយតបខ្លួនឯងនេះផ្ទុយពីចំនុចនេះ។ ម្យ៉ាងទៀត សហព្រះរាជអាជ្ញាបានលើកជាអំណះអំណាងថា "សហព្រះរាជអាជ្ញាមិនបានវិភាគឱ្យបានចប់

---

[9] ដីកាសម្រេច កថាខណ្ឌទី១០ (អក្សរក្នុងលេខយោងលុបចោល) ។

00485561



សព្វគ្រប់លើសំណុំរឿងទាំងមូលនោះទេ ហើយបានស្វែងរកឱ្យបញ្ជូនម្ចាស់បណ្តឹងឧទ្ធរណ៍ទាំងនេះ ទៅជំនុំជម្រះពីទម្រង់នៃការទទួលខុសត្រូវ JCE[10] ទៀតផង ។ ស្របពេលជាមួយគ្នានេះ ចម្លើយបានកំណត់រួចជាស្រេចថា "ការបដិសេធទម្រង់នៃការទទួលខុសត្រូវ JCE នេះ នឹងច្រានចោលទម្រង់នៃការទទួលខុសត្រូវ ដែលបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវពីការប្រព្រឹត្តរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ទាក់ទងនឹងអំពើព្រៃផ្សៃរបស់ខ្មែរក្រហម[11] ។ ដូច្នេះ ចម្លើយតបបានលើកឡើងថា កសព បានសម្រេចចិត្តរួចហើយអំពីការបញ្ចូលសហឧក្រិដ្ឋកម្មរួមនៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ។

15. ការរំលោភវិធាន ២១ មិនបានតម្រូវនោះទេក្នុងការសម្រេចថាតើ បណ្តឹងឧទ្ធរណ៍មួយអាចទទួលយកបាន ក្រោមវិធាន ៧៤(៣) នោះ ។ ក្រៅអំពីការដែលថា ការបដិសេធបណ្តឹងឧទ្ធរណ៍ រំលោភដល់សិទ្ធិរបស់ជនត្រូវក្នុងការទទួលបានការជម្រះក្តីដោយយុត្តិធម៌ មេធាវីការពារក្តីយល់ឃើញថា វាមិនមែនជាធាតុផ្សំដាច់ដោយឡែក ដែលតម្រូវសម្រាប់ការសម្រេចថាតើ ដីកាសម្រេចមួយអាចអនុវត្តបានក្រោមប្រព័ន្ធនៃវិធានផ្ទៃក្នុងនោះ ។

16. មេធាវីការពារក្តីយល់ឃើញថា កសព បន្ថែមដោយមិនត្រឹមត្រូវនូវលក្ខខណ្ឌតម្រូវទៅលើវិធាន ៧៤(៣) ដោយបានស្នើសុំឱ្យអង្គជំនុំជម្រះនេះយល់ឃើញថា សិទ្ធិរបស់ "ម្ចាស់បណ្តឹង" ក្នុងការទទួលបានការជំម្រះក្តីដោយយុត្តិធម៌ មិនត្រូវបានរំលោភនោះទេ ខណៈដែលលក្ខខណ្ឌនេះមិនបង្កើតបានជាផ្នែកមួយនៃវិធានផ្ទៃក្នុង ដែលត្រូវបានបង្កើតឡើងជាពិសេសសម្រាប់ការធ្វើបណ្តឹងដូចជាបណ្តឹងឧទ្ធរណ៍នេះអញ្ចឹងដែរ ។ អំណះអំណាងនេះត្រូវតែបដិសេធចោល ។

## ២.៤ អំណះអំណាងពីសេដ្ឋកិច្ចតុលាការ គឺគ្មានសុពលភាព

### *២.៤.១ ការអនុញ្ញាតលើបណ្តឹងឧទ្ធរណ៍នឹងដាក់បន្ទុកលើការចំណាយរបស់តុលាការនិងសច្ចភាពផ្នែកច្បាប់*

17. អំណះអំណាងចុងក្រោយ កសព លើកឡើងពីការប៉ុនឱ្យបដិសេធបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើមូលហេតុដែលថា តុលាការអាចសន្សំសម្ចៃថវិកាតាមរយៈការបដិសេធចោលបណ្តឹងឧទ្ធរណ៍នេ[12]។ ជាទូទៅ អំណះអំណាងនេះ គឺត្រឹមត្រូវ ប្រសិនបើមានបណ្តឹងឧទ្ធរណ៍ដាក់នៅពេលនេះ តែមេធាវីការពារក្តីយល់ឃើញថា នៅក្នុងករណីនេះ ការដែលហាមឃាត់មិនឱ្យដោះស្រាយលើ

---

[10] កថាខណ្ឌទី២០ នៃចម្លើយតបរបស់ កសព ។

[11] កថាខណ្ឌទី៩៤ នៃចម្លើយតបរបស់ កសព ។

[12] កថាខណ្ឌទី១៨ នៃចម្លើយតបរបស់ កសព ។

00485562



បញ្ហានេះ នៅដំណាក់កាលនេះទេ នោះវាអាចពន្យាដំណើរការនីតិវិធីកាន់តែយូរថែមទៀត និងអាចឈានទៅ រកភាពគ្មានសច្ចភាពនៃការចោទប្រកាន់ទៀតផង ។

18. វាជាការត្រឹមត្រូវក្នុងការសម្រេចលើបញ្ហានេះនៅពេលនេះ ពីព្រោះវានឹងសម្រេចពីវិសាលភាពនៃដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ហើយដីកាដំណោះស្រាយនឹងធ្វើតាមក្រោយ ។ កិច្ចស៊ើបសួរដែលធ្វើឡើងដោយ កសចស បានបញ្ចប់កាលពីប៉ុន្មានខែកន្លងទៅនេះ។ កសព នឹង កសចស អាចដឹងបានថាតើ ពួកគេអាចបញ្ចូល JCE នៅក្នុងដីកាសន្និដ្ឋានស្ថាពរ និងដីកាដំណោះស្រាយ ដែរ ឬយ៉ាងណា ។ សម្រាប់ កសចស អាចធ្វើការសម្រេចយ៉ាងច្បាស់ថា ពួកគេមិនអាចរក្សាការចោទប្រកាន់មកលើជនត្រូវចោទបាននោះទេ ប្រសិនបើពួកគេមិនអាចសំអាងលើសហឧក្រិដ្ឋកម្មរួមជាពិសេស JCE ទម្រង់ទី៣ ។ ការសម្រេចលើបញ្ហានេះ គឺការជាសម្រេចចិត្តមួយដ៏មានសារៈសំខាន់ជាទីបំផុតនៅដំណាក់កាលនេះនៃនីតិវិធី ។

19. ប្រសិនបើអង្គបុរេជំនុំជម្រះយល់ឃើញថា អង្គបុរេជំនុំជម្រះខ្លួនឯងត្រូវបានហាមឃាត់ពីការធ្វើសេចក្តីសម្រេចលើបញ្ហានេះ វិសាលភាពនៃការចោទប្រកាន់នឹងមិនទៀងទាត់ទេ រហូតដល់ការចេញសាលក្រមលើសំណុំរឿង ០០២ ។ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងករណី ឌុច បានសម្រេចថា អង្គជំនុំជម្រះនេះនឹងមិនសម្រេចលើ JCE ទេ រហូតដល់ពេលចេញសាលក្រម[13]។ ការអនុវត្តស្រដៀងគ្នានៅក្នុងសំណុំរឿង ០០២ នឹងនាំទៅរកភាពមិនទៀងទាត់នៅក្នុងការតាក់តែងដីកាដំណោះស្រាយ និងភាពមិនទៀងទាត់នៅដំណាក់កាលសវនាការទាំងមូល ។ ចំនុចនេះនឹងឈាន ទៅរកនូវស្ថានភាពមួយដែលជនត្រូវចោទ មិនត្រូវបានជូនដំណឹងឲ្យបានត្រឹមត្រូវពីវិសាលភាពនៃការចោទប្រកាន់ប្រឆាំងនឹងគាត់ រហូតដល់ចុងបញ្ចប់នៃសវនាការ ។

20. ខណៈដែល កសព បានលើកហេតុផលនៅក្នុងករណី ឌុច ថា កសព បានលើកអំណះអំណាងស្តីពីសហឧក្រិដ្ឋកម្មរួមតែក្រោយពីដីកាដំណោះស្រាយ ប៉ុណ្ណោះ[14] នេះដោយសារតែអំណះអំណាងនេះមិនត្រូវបានជំទាស់ដោយមេធាវីការពារក្តីរបស់ ឌុច ហើយថា ដីកាដំណោះស្រាយក៏បានសម្រេចប្រឆាំងនឹងជំហាររបស់សហព្រះរាជអាជ្ញាដែរ។ ហេតុដូច្នេះហើយទើបថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ២០០៨

---

[13] កសព បានបង្ហាញនៅក្នុងចម្លើយតបរបស់ខ្លួនថា "អង្គជំនុំជម្រះសាលាដំបូងនៅក្នុងករណី ឌុច នឹងសម្រេចតែនៅពេលចេញសាលក្រម ពីភាពអាចអនុវត្តបាននៃ JCE ។ សូមមើល កថាខណ្ឌទី ៨៦ នៃចម្លើយតបរបស់ កសព ។

[14] កថាខណ្ឌទី១៩ នៃចម្លើយតបរបស់ កសព ។

កសព ប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងករណី ឌុច និងបានលើកបញ្ហានោះនៅចំពោះមុខអង្គបុរេជំនុំជម្រះនៅដំណាក់នោះ[15]។

21. ម្យ៉ាងទៀត កសព បានយោងថា កសចស ប្រើពេលមួយឆ្នាំកន្លះ ចាប់ពីថ្ងៃដែលញ្ញត្តិលើកដំបូងដែលដាក់ដោយក្រុមការពារ អៀង សារី[16] ទម្រាំចេញសេចក្ដីសម្រេចរបស់ខ្លួន។ មេធាវីការពារក្ដីសូមសង្កត់ធ្ងន់ថា ចំនុចនេះមិនត្រូវប្រើប្រាស់ជាអំណះអំណាងមិនអនុញ្ញាតលើបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដីឡើយ ។

*២.៤.២ សេចក្ដីសម្រេចប្រឆាំងគ្នា អាចកើតចេញពីប្រព័ន្ធច្បាប់*

22. កសព បានអះអាងថា អាចមានទំនាស់រវាងសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ និងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[17] គឺកើតចេញពីប្រព័ន្ធនៅ អវតក នៅពេលដែលសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះត្រូវបានផ្ដល់អំណាចដោយវិធានផ្ទៃក្នុង ដើម្បីសម្រេចលើបញ្ហាផ្នែកច្បាប់ ជាពិសេស បញ្ហាយុត្តាធិការ និងនៅពេលដែលអង្គជំនុំជម្រះសាលាដំបូងអាចសម្រេចលើបញ្ហាទាំងនោះនៅចុងបញ្ចប់នៃនីតិវិធី ។ វាជាការត្រឹមត្រូវដែលបញ្ហាផ្នែកច្បាប់នានាត្រូវបានលើកឡើងនៅដំណាក់កាលស៊ើបសួរ ដែលអាចពាក់ព័ន្ធនៅដំណាក់កាលសវនាការដែរ ។

23. មេធាវីការពារក្ដីសូមស្នើបន្ថែមទៀតថា កសព ត្រូវតែបានហាមឃាត់ពីការធ្វើអំណះអំណាង ដែលទាក់ទងនឹងការធ្វើឲ្យមានការប្រឆាំងគ្នារវាងសេចក្ដីសម្រេចនានាដោយអង្គជំនុំជម្រះផ្សេងៗពីគ្នា។ នៅក្នុងសំណុំរឿង ០០១ ប្រឆាំងនឹង ឌុច បញ្ហានៃការអនុវត្តសហឧក្រិដ្ឋកម្មរួមត្រូវបានសម្រេចដោយអង្គបុរេជំនុំជម្រះ ។ ប៉ុន្តែ ដោយសារតែអង្គបុរេជំនុំជម្រះបានសម្រេចប្រឆាំងនឹងជំហររបស់ កសព នៅក្នុងករណីនោះ ហេតុដូច្នេះ គឺ កសព ខ្លួនឯងទេដែលសម្រេចលើកបញ្ហានេះម្ដងទៀតនៅឯសវនាការ ហើយបានជំរុញឲ្យអង្គជំនុំជម្រះសាលាដំបូងចេញសេចក្ដីសម្រេច ដែលប្រឆាំងនឹងសេចក្ដីសម្រេចលើកមុនលើបញ្ហាដូចគ្នា ដែលចេញដោយអង្គបុរេជំនុំជម្រះ។ កសព បានផ្ដល់

---

[15] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាដំណោះស្រាយបញ្ជូនជនត្រូវចោទ កាំង ហ្កេកអ៊ាវ "ឌុច" ទៅជំនុំជម្រះ ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០០៨, ថ្ងៃទី៥ ខែ កញ្ញា ២០០៨, សំណុំរឿង ០០១ ឯកសារលេខ D99/3/3 ។

[16] បណ្ដឹងរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តនៅ អវតក នូវទម្រង់នៃការទទួលខុសត្រូវ ដែលគេស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៨, ឯកសារ D97 ។

[17] កថាខណ្ឌទី១៨ នៃចម្លើយតបរបស់ កសព ។

អំណះអំណាងបន្ថែមទៀត ទាក់ទងនឹងមូលហេតុដែលអង្គជំនុំជម្រះសាលាដំបូងត្រូវតែច្រានចោល នូវសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនោះ[18] ។ សហព្រះរាជអាជ្ញាយល់ឃើញថា:

> សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងការកំណត់បទល្មើស មិនចងកាតព្វកិច្ចផ្លូវច្បាប់ដល់អង្គជំនុំជម្រះសាលាដំបូងនោះទេ។ ហេតុដូច្នេះ បើទោះបីជាអង្គបុរេជំនុំជម្រះបានសម្រេចជាបឋមទៅលើភាពអនុវត្តបាននៃ JCE ក៏ដោយ ក៏អង្គជំនុំជម្រះសាលា ដំបូងអាចលើកបញ្ហានោះដោយឆន្ទានុសិទ្ធិរបស់ខ្លួនបានដែរ ហើយការកែប្រែការកំណត់បទល្មើសផ្អែកទៅលើអង្គហេតុ ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជម្រះ ហើយអង្គហេតុដែលត្រូវបានបង្ហាញនៅក្នុងសវនាការ ។ ការបន្ថែម JCE ជាទម្រង់នៃការទទួលខុសត្រូវ គឺសមស្រប ពីព្រោះអង្គបុរេជំនុំជម្រះមានកំហុសនៅក្នុងការសម្រេចថា JCE មិនអាចអនុវត្តបានទេ[19] ។

24. ក្នុងករណីដែលទំនាស់អាចកើតឡើង រវាងសេចក្តីសម្រេចដែលធ្វើឡើងដោយអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង គឺកើតចេញពីប្រព័ន្ធច្បាប់នៅ អវតក ។ វាមិនត្រូវបានគេយល់ឃើញថាជាបញ្ហានោះទេ ជាពិសេស ដោយសារតែការសម្រេចនានាពាក់ព័ន្ធទៅនឹងដំណាក់កាលខុសៗគ្នានៃនីតិវិធី ។ កសព ត្រូវតែបានហាមឃាត់ពីការលើកឡើងនូវអំណះអំណាងនេះ ហើយអំណះអំណាងបែបនេះត្រូវតែបានបដិចោលចោល ដោយផ្អែកលើមូលហេតុ និងខ្លឹមសារទាំងនោះ ។

## ២.៤.៣ *បញ្ហាដែលបានលើកឡើងនៅទីនេះ មានលក្ខណៈផ្ទុយគ្នាពីបញ្ហាដែលនឹងត្រូវលើកឡើងក្នុងសវនាការ*

25. ជាងនេះទៅទៀត ដោយផ្ទុយពីការអះអាងរបស់ ក.ស.ព បញ្ហាដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍នេះ អាចមានទំនាក់ទំនងទៅនឹងបញ្ហាដែលនឹងត្រូវបានគេលើកឡើងក្នុងសវនាការ និងជាពិសេស មានទំនាក់ទំនងទៅនឹងបញ្ហាដែលកើតឡើងទៅនឹងដំណាក់កាលស៊ើបអង្កេតផងដែរ ។

26. សារណាមួយក្នុងចំណោមសារណាជាច្រើនរបស់ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ ពាក់ព័ន្ធទៅនឹងការផ្តល់មូលហេតុមិនត្រឹមត្រូវអំពីសហឧក្រិដ្ឋកម្មរួមនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ហេតុដូច្នេះ បញ្ហានេះ ត្រូវតែបានដោះស្រាយដោយអង្គបុរេជំនុំជម្រះ ។

---

[18] សំណើរបស់ កសព ស្នើសុំអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០០៩ សំណុំរឿង ០០១, ឯកសារ E73 ។

[19] សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឲ្យមានអនុវត្ត JCE ចុះថ្ងៃទី ៨ ខែ មិថុនា សំណុំរឿង ០០១, ឯកសារ E73 ។

### ២.៤.៤ *សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងករណី ឌុច មិនបានសម្រេចបញ្ហានៅក្នុងសំណុំរឿង ០០២ ទេ*

27. ក.ស.ព អះអាងក្នុងករណីក្តី ឌុច ថា មេធាវីការពារក្តីធ្វើការតវ៉ា "ស្ទើរតែដូចគ្នាបេះបិទ" ដែលឥឡូវនេះត្រូវតែបានដោះស្រាយភ្លាមៗដោយអង្គជំនុំជម្រះសាលាដំបូង ។ ក្រុមមេធាវីការពារក្តីចង់បញ្ជាក់ថា ក្រុមមេធាវីការពារក្តីក្នុងសំណុំរឿង ០០២ ត្រូវបានបដិសេធមិនឱ្យដាក់អំណះអំណាងនៅក្នុងរឿងក្តីនោះ ហើយក្រុមមេធាវីការពារក្តី ឌុច បានប្រកាន់យកនូវឥរិយាបទស្ងប់ស្ងៀមក្នុងអំឡុងសវនាការ ដែលធ្វើឱ្យអង្គជំនុំជម្រះមិនអាចទទួលបាននូវសារៈប្រយោជន៍ពីអំណះអំណាងតាមផ្លូវច្បាប់ពេញលេញណាមួយតទល់នឹងទស្សនៈប្រឆាំង ។ នៅក្នុងករណីនេះ ការសម្រេចរបស់ អង្គបុរេជំនុំជម្រះទៅលើសហឧក្រិដ្ឋកម្មរួម នៅក្នុងករណី ឌុច មិនអាចកំណត់ពីវិសាលភាព នៅក្នុងសំណុំរឿង០០២ បានទេ ។

28. ដោយយោងទៅលើសេចក្តីសម្រេចលើសំណើរបស់ អៀង សារី ស្នើសុំដាក់សារណាស្តីពីការអនុវត្តនូវទ្រឹស្តីសហឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាំង ហ្គេចអ៊ាវ ហៅ ឌុច ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានលើកឡើងថា៖

> អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងបញ្ហានៃការអនុវត្តទ្រឹស្តីសហឧក្រិដ្ឋកម្មរួម ជនត្រូវចោទ អៀង សារី មិនមានសិទ្ធចូលអន្តរាគមន៍នៅក្នុងរឿងក្តីប្រឆាំងជនត្រូវចោទ ឌុច ទេ ។ អង្គបុរេជំនុំជម្រះក៏យល់ឃើញទៀតថា សាលដីកាបស់ខ្លួនមិនពាក់ព័ន្ធដោយផ្ទាល់ចំពោះលោក អៀង សារី ឡើយ ហើយលោក អៀង សារី នៅតែមានលទ្ធភាពផ្តល់អំណះអំណាងចំពោះការអនុវត្តទ្រឹស្តីសហឧក្រិដ្ឋកម្មរួម នៅក្នុងសំណុំរឿងដែលគាត់ជាភាគី[20]។

29. ដូចគ្នានះដែរ ការកំណត់ពីវិសាលភាពនៃការចោទប្រកាន់ប្រឆាំង ឌុច ដោយអង្គជំនុំជម្រះសាលាដំបូង នឹងមិនកំណត់ពីវិសាលភាពនៃការចោទប្រកាន់ប្រឆាំងជនត្រូវចោទដទៃទៀតទេ។ ដូច្នេះ ការរង់ចាំឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចទៅលើភាពអាអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមនៅក្នុងរឿងក្តីប្រឆាំង ឌុច នឹងក្លាយទៅជារឿងឥតប្រយោជន៍នៅក្នុងការសម្រេចបញ្ហានេះទេ។

30. ម្យ៉ាងវិញទៀត ការមិនអនុញ្ញាតលើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើមូលដ្ឋានដែលបានលើកឡើងនៅក្នុងសារណារបស់ ក.ស.ព នឹងបង្កើតបានករណីយុត្តិសាស្ត្រមួយ ដែលអង្គបុរេជំនុំជម្រះមិនអាច

---

[20] អ.ប.ជ, សេចក្តីសម្រេចស្តីពី សំណើរួមនិងបន្ទាន់របស់ក្រុមមេធាវីការពារក្តី ដើម្បីធ្វើអន្តរាគមន៍ ទៅលើបញ្ហាទាក់ទងនឹង សហឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍ របស់ ក.ស.ព ប្រឆាំងដីការដំណោះស្រាយ ទៅលើ ឌុច ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៨, សំនុំរឿងលេខ 001/18-07-2007-ECCC/OCIJ (PTC 02), ឯកសារលេខ D99/3/31,កថាខណ្ឌទី៥។

00485566



ដោះស្រាយលើបញ្ហានានាបាន ព្រោះបញ្ហាទាំងនេះអាចនឹងត្រូវបានគេលើកឡើងម្តងទៀតនៅពេលណាមួយក្នុងដំណាក់កាលជំនុំជម្រះ។ ដំណោះស្រាយបែបនេះ គឺផ្ទុយទៅនឹងបទបញ្ញត្តិដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង។

## III. ចម្លើយតបទៅនឹងសេចក្តីសន្និដ្ឋានស្តីពីនីតិវិធី ដែលលើកឡើងដោយ ក.ស.ព

31. ក.ស.ព បានលើកបញ្ហាជាច្រើននៅក្នុងជំពូក៣ ទាក់ទងទៅនឹងពីនីតិវិធី ។ មេធាវីការពារក្តីយល់ឃើញថា បញ្ហាទាំងនេះត្រូវតែដោះស្រាយនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ឬបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទដទៃទៀត។

32. ទោះបីជាយ៉ាងណាក៍ដោយ ក្រុមមេធាវីការពារក្តីបានឆ្លើយតបទៅនឹងផ្នែក IV-E នៃសេចក្តីសន្និដ្ឋានតបរបស់ ក.ស.ព ទាក់ទងនឹងការផ្តល់អំណះអំណាងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

33. អំណះអំណាងទាក់ទងនឹងការផ្តល់មូលហេតុមិនត្រឹមត្រូវ ស្តីពីសហឧក្រិដ្ឋកម្មរួមដែលបានលើកឡើង នៅក្នុងពាក្យសុំ[21]របស់ អៀង ធីរិទ្ធ ប្រឆាំងទៅនឹងការអនុវត្តសហឧក្រិដ្ឋកម្មរួម និងបណ្តឹងឧទ្ធរណ៍[22] របស់ អៀង ធីរិទ្ធ បានដាក់បញ្ចូលនៅក្នុងចម្លើយតបនេះ។

34. មេធាវីការពារក្តី យល់ឃើញថាទម្រង់ទី១ និងទី៣ នៃសហឧក្រិដ្ឋកម្មរួម មិនត្រូវបានផ្តល់មូលហេតុឲ្យបានត្រឹមត្រូវនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះទេ ពីព្រោះពុំមានមូលដ្ឋានពិតប្រាកដ ត្រូវបានបញ្ជាក់ពីទម្រង់នៃការចូលរួមទាំងនេះទេ។ កថាខណ្ឌ៥ ដល់ ១៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ បានសំដៅទៅលើទម្រង់ទី២នៃសហឧក្រិដ្ឋកម្មរួម តែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត សេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបានបញ្ចូលទម្រង់ទី១ និងទី៣ នៃសហឧក្រិដ្ឋកម្មរួមផងដែរ ប៉ុន្តែ ពុំបានបញ្ជាក់ឲ្យបានច្បាស់អំពីទម្រង់ទាំងពីរនេះទេនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ ហើយក៏គ្មានមូលដ្ឋានពិតប្រាកដណាមួយត្រូវបានគេផ្តល់ ដើម្បីគាំទ្រទម្រង់ទី១ និងទី៣នេះក៏ទេដែរ ។ ដូច្នេះទម្រង់ទាំងពីរនេះ ត្រូវបានគេសន្និដ្ឋានខុស ហើយខ្វះភាពប្រាកដប្រជា និងភាពជាក់លាក់ ដែលតម្រូវឲ្យមានដោយអង្គបុរេជំនុំជម្រះ ។

---

[21] សារណារបស់ អៀង ធីរិទ្ធ ស្តីពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវរួម ដែលគេស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម អនុលោមទៅតាមដីការបស់ សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ និង ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨, ឯកសារលេខ D97/3/2។

[22] បណ្តឹងឧទ្ធរណ៍ របស់ អៀង ធីរិទ្ធ , មូលហេតុនៃបណ្តឹងឧទ្ធរណ៍៣។

35. នៅក្នុងរឿងក្តីប្រឆាំង ឌុច អង្គបុរេជំនុំជម្រះលើកឡើងថា សហឧក្រិដ្ឋកម្មរួមត្រូវបានគេសន្និដ្ឋានខុសនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ព្រោះថាវាមានគ្មានភាពច្បាស់លាស់ និងជាក់លាក់ អង្គបុរេជំនុំជម្រះបញ្ជាក់ថា ការតម្រូវឱ្យមានភាពច្បាស់លាស់ គឺ "ដើម្បីវិភាគថាតើទម្រង់ផ្សេងគ្នានៃសហឧក្រិដ្ឋកម្មរួមនេះ អាចត្រូវបានអនុវត្តដែរ ឬទេ និង ដើម្បីញែកឱ្យដាច់ស្រលះរវាងទស្សនៈសហឧក្រិដ្ឋកម្មរួម និងទម្រង់នៃការទទួលខុសត្រូវប្រហាក់ប្រហែលគ្នានេះដទៃទៀត ដែលអាចអនុវត្តបានក្រោមច្បាប់កម្ពុជា"[23]។ អង្គបុរេជំនុំជម្រះបានលើកឡើងថា ចាប់តាំងពី ក.ស.ព បានដាក់ការសន្និដ្ឋានខុសអំពីសហឧក្រិដ្ឋកម្មរួម នៅក្នុងសំណុំរឿងនោះបន្ទាប់ពីដំណាក់ការស៊ើបអង្កេត "សហឧក្រិដ្ឋកម្មរួម មិនបង្កើតជាផ្នែកនៃមូលដ្ឋានពិតប្រាកដសម្រាប់ការស៊ើបអង្កេតឡើយ ហើយដោយសារមូលហេតុនេះ អង្គបុរេជំនុំជម្រះនឹងមិនដាក់បញ្ចូលសហឧក្រិដ្ឋកម្មរួម ទៅក្នុងដីកាដំណោះស្រាយនៅក្នុងដំណាក់កាលនោះទេ"[24]។ ដូច្នេះ ចំនុចនេះ ក៏អាចអនុវត្តបាននៅក្នុងនីតិវិធីនេះដែរ ។

36. បញ្ហាមួយផ្សេងទៀត ដែល ក.ស.ព បានលើកឡើងក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន ទាក់ទងទៅនឹងមូលហេតុនៃ បណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តី ដែលថាការបង្កើតទម្រង់ទី៣ នៃសហឧក្រិដ្ឋកម្មរួម ដោយ ដីកាសម្រេចរបស់ ក.ស.ច.ស គឺមានលក្ខណៈមិនច្បាស់លាស់ ។ ក.ស.ព បានពន្យល់ ដីការបស់ កសចស ត្រង់ចំនុចនេះគឺជាអាជ្ញាកណ្តាល ហើយប្រាប់កុំឱ្យចាប់អារម្មណ៍ពីបញ្ហានេះតទៅទៀត[25]។ មេធាវីការពារក្តីយល់ឃើញថា បញ្ហានេះកើតចេញពីដីការបស់ ក.ស.ច.ស ហើយដោយសារតែដីកានេះមិនមានភាពច្បាស់លាស់ និងខ្វះភាពជាក់លាក់ នោះដីកានេះត្រូវតែត្រូវចាត់ទុកជាអសាឥតការ ដោយផ្អែកលើមូលដ្ឋានខាងលើ ។ ជាងនេះទៅទៀត វាមិនមែនជារឿងត្រឹមត្រូវទេដែល ក.ស.ព អះអាងថា ក.ស.ច.ស ត្រូវតែបានដាក់កម្រិត "ដើម្បីយល់ថា ប្រសិនបើសហឧក្រិដ្ឋកម្មរួមគួរអនុវត្តនៅចំពោះមុខអ.វ.ត.ក[26]នោះ ។ ដំណោះស្រាយដែលស្នើដោយមេធាវីការពារក្តី ពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក ក្នុងការកាត់ទោសជនត្រូវចោទ ដោយផ្អែកលើមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម ហើយច្បាស់ជាងនេះទៅទៀត គឺដើម្បីដកទម្រង់ទី២ នឹងទី៣ នៃសហឧក្រិដ្ឋកម្មរួម ដូច្នេះ ក.ស.ព បានផ្តល់ការសន្និដ្ឋាន

---

[23] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ ចោទប្រកាន់ កាំង ហ្គេច អ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ២០០៨, សំនុំរឿង០០១, ឯកសារ លេខ D99/3/42, កថាខណ្ឌ១៣៥។

[24] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ ចោទប្រកាន់ កាំង ហ្គេច អ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ២០០៨, សំនុំរឿង០០១, ឯកសារ លេខ D99/3/42, កថាខណ្ឌ១៤១។

[25] ចំលើយតបរបស់ ក.ស.ព កថាខណ្ឌ៨៥

[26] ចំលើយតបរបស់ ក.ស.ព កថាខណ្ឌ៨៥

មិនត្រឹមត្រូវ អំពីទម្រង់ទី១ និងទី៣ នៃសហឧក្រិដ្ឋកម្មរួម ក្នុងដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដូច្នេះសហឧក្រិដ្ឋកម្មរួម មិនអាចយកទៅអនុវត្តក្នុងសំនុំរឿង០០២ បានទេ[27]។

## IV. សេចក្តីសន្និដ្ឋាន

37. ដូច្នេះ យោងតាមហេតុផលដូចដែលបានគូសបញ្ជាក់នៅទីនេះ មេធាវីការពារក្តីសូមស្នើដល់អង្គជំនុំជម្រះ បដិសេធចោលដីកានេះ ហើយជំនួសមកវិញ សូមស្នើឲ្យអង្គបុរេជំនុំជម្រះយល់ឃើញថា៖

(ក) ជាបឋម អវតក មិនមានយុត្តាធិការទៅលើសហឧក្រិដ្ឋកម្មរួម ជាទម្រង់នៃការទទួលខុសត្រូវរួមនោះទេ,

(ខ) ម្យ៉ាងវិញទៀត អវតក មិនមានយុត្តាធិការអនុវត្តទម្រង់ទី២ និងទី៣ នៃសហក្រិដ្ឋកម្មរួមនោះទេ

(គ) ជាងនេះទៅទៀត សហព្រះរាជអាជ្ញា មិនបានធ្វើការអះអាងឲ្យបានគ្រប់គ្រាន់អំពីទម្រង់ទី ១ និងទី៣ នៃសហឧក្រិដ្ឋកម្មរួម នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដូច្នេះហើយ ទម្រង់ទាំងពីរនេះ មិនអាច អនុវត្តក្នុងសំណុំរឿង០០២ ទេ។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះរបស់មេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី១៥ ខែ មិនា ឆ្នាំ ២០១០ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | |

[27] សារណារបស់ អៀង ធីរិទ្ធ ស្តីពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវរួម ដែលគេស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម អនុលោមទៅតាមដីការបស់ សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ និង ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨, ឯកសារលេខ D97/3/2។